# កិច្ចព្រមព្រៀងបន្ថែមនៅលើកិច្ចព្រមព្រៀងបំពេញបន្ថែម
# រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា
# បន្ថែមនៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ
# ទាក់ទងនៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម
# ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
# ស្ដីពីការរៀបចំសុវត្ថិភាព និងសន្តិសុខ

**ដោយរំលឹក**អំពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ក្នុងទីក្រុងភ្នំពេញ (តទៅនេះហៅថា "**កិច្ចព្រមព្រៀង**")។

**ដោយរំលឹកបន្ថែមទៀត** អំពី**កិច្ចព្រមព្រៀងបំពេញបន្ថែម**រវាងអង្គការសហប្រជាជាតិ

និង រាជរដ្ឋាភិបាលកម្ពុជា បន្ថែមទៅលើកិច្ចព្រមព្រៀងស្ដីពីការរៀបចំសុវត្ថិភាព និងសន្តិសុខ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ("**កិច្ចព្រមព្រៀបំពេញបន្ថែម**")

**ដោយកត់សម្គាល់ថា** ទំហំ និងមុខងាររបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានកាត់បន្ថយជាច្រើន អនុលោមតាម**កិច្ចព្រមព្រៀងបន្ថែម**ទៅលើ**កិច្ចព្រមព្រៀង**ដែលបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ទាក់ទងនឹងការបំពេញមុខងារសេសសល់ ដែលបានចូលជាធរមាននៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២១

**ដោយកត់សម្គាល់** ការបញ្ចប់កិច្ចដំណើរការនីតិវិធីតុលាការក្នុងខែធ្នូ ឆ្នាំ២០២២ និងការចាប់ផ្ដើមមុខងារសេសសល់នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣

**ដោយហេតុថា** ភាគីទៅនឹងកិច្ចព្រមព្រៀងជឿជាក់ថា ផ្អែកលើទំហំ និងមុខងាររបស់អង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានកាត់បន្ថយ តម្រូវការសម្រាប់ការរៀបចំសុវត្ថិភាព និងសន្តិសុខយោងតាម**កិច្ចព្រមព្រៀងបំពេញបន្ថែម** គប្បីសមាមាត្រទៅនឹងទំហំ និងមុខងារដែលបានកាត់បន្ថយនោះដែរ

**អាស្រ័យហេតុនេះ** អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាព្រមព្រៀងដូចខាងក្រោម៖

## មាត្រា ១ - អាគារ

រាជរដ្ឋាភិបាលកម្ពុជា អនុលោមតាមការទទួលខុសត្រូវរបស់ខ្លួនដូចមានចែងក្នុងមាត្រា ១៤ នៃ**កិច្ចព្រមព្រៀង** ត្រូវផ្ដល់និងត្រូវរ៉ាប់រងការចំណាយដោយខ្លួនឯង នូវផ្នែកខ្លះនៃអាគារដែលមានទីតាំងស្ថិតនៅអាគារលេខ ៤៦ មហាវិថីស៊ហាត់នួរុស្សី (វិថី ១១០) សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ជាអាគាររបស់អង្គជំនុំជម្រះវិសាមញ្ញសម្រាប់រយៈពេលនៃរយៈកាលមុខងារសេសសល់។

## មាត្រា ២ - គោលការណ៍ និងនីតិវិធីសន្តិសុខ

១. មុខងារ និងការទទួលខុសត្រូវរបស់ប្រធានសន្តិសុខអន្តរជាតិ និងអនុប្រធានសន្តិសុខអន្តរជាតិ តទៅនេះនឹងត្រូវអនុវត្តដោយមន្ត្រីសម្របសម្រួលជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្ដីខ្មែរក្រហម (UNAKRT)។

២.	អង្គការសហប្រជាជាតិនឹងផ្តល់បុគ្គលិកសន្តិសុខម្នាក់ ដែលនឹងត្រូវទំនាក់ទំនង និងសម្របសម្រួលសកម្មភាពប្រចាំថ្ងៃជាមួយប្រធានសន្តិសុខជាតិ ក៏ដូចជាបំពេញភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យអាគារអន្តរជាតិ ដែលមានចែងក្នុងមាត្រា ៥ កថាខណ្ឌ ២ នៃកិច្ចព្រមព្រៀងបំពេញបន្ថែម។

៣.	អង្គការសហប្រជាជាតិត្រូវផ្តល់ឱ្យសម្រាប់ការបំពេញមុខងាររបស់មន្ត្រីសន្តិសុខសាលសវនាការអន្តរជាតិ អ្នកស៊ើបអង្កេតសន្តិសុខអន្តរជាតិ មន្ត្រីសន្តិសុខព័ត៌មានអន្តរជាតិ មន្ត្រីការពារផ្ទាល់អន្តរជាតិ និងមន្ត្រីសន្តិសុខអន្តរជាតិ តាមមូលដ្ឋាន*ចំពោះកិច្ច* ដូចដែលត្រូវការសម្រាប់ប្រតិបត្តិការ។

## មាត្រា ៣ - ការចូលជាធរមាន

កិច្ចព្រមព្រៀងបន្ថែមនេះត្រូវចូលជាធរមានភ្លាមបន្ទាប់ពីចុះហត្ថលេខា។

## មាត្រា ៤ - ការបញ្ចប់

កិច្ចព្រមព្រៀងបន្ថែមនេះត្រូវនៅជាធរមានដរាបណា**កិច្ចព្រមព្រៀងបំពេញបន្ថែម**នៅជាធរមាន។ កិច្ចព្រមព្រៀងបន្ថែមនេះត្រូវបញ្ចប់នៅពេលដែល**កិច្ចព្រមព្រៀងបំពេញបន្ថែម**បញ្ចប់។

តំណាងរបស់ភាគីដែលត្រូវបានផ្តល់សិទ្ធិអំណាចត្រឹមត្រូវតាមច្បាប់ បានចុះហត្ថលេខានៅទីក្រុងភ្នំពេញ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

**ភាគីរាជរដ្ឋាភិបាលកម្ពុជា**

*ហត្ថលេខា*
**ហែម ក្រាញ់តូនី**
**រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានការិយាល័យរដ្ឋបាលស្តីទី នៃ អ.វ.ត.ក.**

**ភាគីអង្គការសហប្រជាជាតិ**

*ហត្ថលេខា*
Knut Rosandhaug
**មន្ត្រីសម្របសម្រួលជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម**